


# កំរិតជីប្រើប្រាស់សំរាប់ដំណាំចំការក្នុងប្រទេសកម្ពុជា

ឯកសារនេះ មានគោលបំណងផ្តល់នូវអនុសាសន៍ ក្នុងការប្រើប្រាស់ជីសំរាប់ផលិតកម្មដំណាំ ពោត សណ្តែកសៀង សណ្តែកបាយ សណ្តែកដី និងល្ង នៅប្រទេសកម្ពុជា។ សំរាប់ពេលនេះ អនុសាសន៍នេះមានគោលបំណងសំរាប់តែអ្នកស្រាវជ្រាវយកទៅប្រើប្រាស់ប៉ុណ្ណោះ។ កំរិតជីណែនាំនេះត្រូវបានកំណត់ដោយផ្អែកលើកំរិតជីប្រើប្រាស់សំរាប់នៅអាស៊ីអាគ្នេយ៍ ដែលកំណត់ដោយ Dierolf *et al*. (2001)[1] ហើយត្រូវបានកែតំរូវសំរាប់ប្រទេសកម្ពុជា ផ្អែកលើទិន្នផលរំពឹងទុកនៃដំណាំនីមួយៗ ទិន្នន័យនៃពិសោធន៍មួយចំនួននៅកម្ពុជា និងកំរិតជីជាតិនៃប្រភេទដីផ្សេងៗដូចមានក្នុងរបាយការណ៍របស់ White *et al*. (1997)[2] និង CIAP (1999)[3] សំរាប់ការលូតលាស់របស់ដំណាំស្រូវ នៅលើដីទាំងនេះ (តារាងទី១ និងទី២)។ ចំពោះតំរូវការមីក្រូធាតុត្រូវធ្វើការពិនិត្យ និងតាមដានជាបន្តទៀត។

**តារាងទី១:** កំរិតជីណែនាំប្រើប្រាស់សំរាប់ដំណាំពោត សណ្តែកសៀង សណ្តែកបាយ សណ្តែកដី និង ល្ង តំរូវទៅតាមប្រភេទដី។

| ឈ្មោះជី | កំរិតជីទៅតាមប្រភេទដី [A] (គក្រ/ហត) | | | | | |
|---|---|---|---|---|---|---|
| | ព្រៃខ្មែរ | ប្រទះឡាង | កំពង់សៀម | ឡាបានសៀក | ទួលសំរោង | កៀនស្វាយ |
| Urea | 124 | 124 | 174 | 174 | 174 | 150 |
| DAP | 95 | 95 | 107 | 107 | 107 | 85 |
| KCl | 37 | 37 | 45 | 45 | 37 | 54 |
| 16-16-8-13S | 100 | 100 | 100 | 100 | 100 | 100 |
| $ZnSO_4$ | 20 | 20 | 5 | 5 | 20 | 20 |
| $CuSO_4$ | 5 | 5 | 2 | 2 | 5 | 5 |
| $MoO_3$ | 0.5 | 0.5 | 0.5 | 0.5 | 0 | 0 |
| $H_3BO_3$ | 2 | 2 | 5 | 5 | 5 | 5 |

[A] ដើម្បីកំណត់ប្រភេទដី សូមមើលឯកសារ White *et al*. (1997).

ជី Urea អាចមិនបាច់ប្រើប្រាស់ ហើយ DAP អាចជំនួសដោយ Monoammonium phosphate (MAP) ក្នុងកំរិតដូចគ្នា បើសិនជាដឹងថាពួកដំណាំសាកជាតិ (សណ្តែកដី សណ្តែកសៀង និងសណ្តែកបាយ) បង្កើតពកឫស និងចាប់យកអាសូត (N) គ្រប់គ្រាន់។ ធ្វើដូច្នេះអាចបន្ថយកំរិតប្រើប្រាស់ N ពី ៧0-៧៥% ហើយបង្កើនកំរិតប្រើប្រាស់ $P_2O_5$ ប្រហែល ៧% នៃកំរិតដែលបានបង្ហាញនៅក្នុងតារាងទី២។

**តារាងទី ២:** បំលែងកំរិតជីទៅជាកំរិតសារធាតុចិញ្ចឹមប្រើប្រាស់ទៅតាមប្រភេទដី

| ឈ្មោះសារធាតុចិញ្ចឹម | កំរិតជីទៅតាមប្រភេទដី [B] (គក្រ/ហត) | | | | | |
|---|---|---|---|---|---|---|
| | ព្រៃខ្មែរ | ប្រទះឡាង | កំពង់សៀម | ឡាបានសៀក | ទួលសំរោង | កៀនស្វាយ |
| N | 90 | 90 | 115 | 115 | 115 | 100 |
| $P_2O_5$ | 60 | 60 | 65 | 65 | 65 | 55 |
| $K_2O$ | 30 | 30 | 35 | 35 | 30 | 40 |
| S | 13-18 | 13-18 | 13-18 | 13-18 | 13-18 | 13-18 |

[B] ដើម្បីបំលែង $P_2O_5$ ទៅ P ត្រូវគុណនឹង 0.44 និង $K_2O$ ទៅ K ត្រូវគុណនឹង 0.83

## របៀបដាក់ជី

ជាការសំខាន់ណាស់ ដែលត្រូវអនុវត្តឱ្យបានត្រឹមត្រូវទៅតាមវិធីសាស្ត្រនៃការដាក់ជី ដើម្បីកាត់បន្ថយការបាត់បង់សារធាតុចិញ្ចឹមរបស់ជី ហើយបង្កើនប្រសិទ្ធិភាពរបស់វា និងបង្កើនប្រសិទ្ធភាពក្សេត្រវិទ្យា។ ការមិនបានអនុវត្តត្រឹមត្រូវតាមបច្ចេកទេសអាចទទួលបានទិន្នផលទាប និងមានភាពចំណេញតិច។ ក្រោយពីកំណត់បានបរិមាណជីសមស្រប ត្រូវគិតគូរពីកត្តាពេលវេលា និងទីតាំងដាក់ជី ព្រោះវាជាកត្តាសំខាន់បំផុត ដើម្បីឱ្យមានជោគជ័យក្នុងការប្រើប្រាស់ជី។ យើងសូមលើកឡើងនូវវិធីសាស្ត្រដូចតទៅ:

1. ប្រើប្រាស់ ៥០% នៃជីជាតិ N និង K រួមនឹងជីដែលត្រូវប្រើផ្សេងទៀត ជាជីទ្រាប់បាតនៅពេលដាំ (បើសិនជាដំណាំមានពកឬសល្អ ហើយជី MAP ត្រូវប្រើជំនួស DAP នោះ MAP ត្រូវប្រើជាជីទ្រាប់បាតទាំងអស់)។
2. ជីជាតិ N និង K ដែលនៅសល់ ត្រូវដាក់នៅពេល ៣-៤ សប្តាហ៍ក្រោយពេលដាំ។
3. លាយច្របល់ជីបញ្ចូលគ្នាឱ្យបានសព្វល្អ រួចបាចវាភ្លាម។ មិនត្រូវពន្យាពេលដាក់ជីទេ បន្ទាប់ពីច្របល់វាបញ្ចូលគ្នារួច ព្រោះអាចធ្វើឱ្យមានការបាតបង់សារធាតុចិញ្ចឹមច្រើន ហើយអាចធ្វើឱ្យជីកកក្តាំងជាដុំៗជាប់គ្នា ដែលមិនអាចមានប្រសិទ្ធភាពប្រើប្រាស់បាន។
4. ត្រូវដាក់ជីទៅតាមរណ្តៅដែលត្រូវដាំដុះ រួចលុបដីមុននឹងដាំដុះដំណាំ ដើម្បីកាត់បន្ថយការបាត់បង់ដោយការភាយ (N) និងដោយការហូរចេញ និងការហូរច្រោះ (P, K)។
5. ការដាក់ជីទ្រាប់បាត គួរតែធ្វើមុនពេលដាំ ១-២ ថ្ងៃ ដើម្បីជៀសវាងការខ្លោចកូនដំណាំ។

### កំណត់សំគាល់:

- គួរតែដាក់ជីក្រោយពេលដកស្មៅរួច ពីព្រោះការធ្វើដូច្នេះ ជីនឹងមិនមានការបាត់បង់ច្រើនដោយសារស្មៅស្រូបយកឡើយ។
- គួរតែដាក់ជីជាតិ N តែនៅពេលដែលដីមានសំណើមគ្រប់គ្រាន់ ដើម្បីឱ្យដំណាំស្រូបយកជីជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ដី ដែលមានសមាសធាតុអំបិលខ្ពស់ ធ្វើឱ្យមានការស្រូបយកជាតិទឹកពីគ្រាប់ពូជ ដែលរំខានដល់ដំណុះគ្រាប់។
- ពេលដាក់ជីបំប៉នត្រូវឱ្យគ្រាប់ជីធ្លាក់លើដី មិនត្រូវឱ្យវាទើជាប់លើស្លឹកដំណាំទេ។ គ្រាប់ជីអាចធ្វើឱ្យខ្លោចស្លឹក ឬក៏អាចធ្វើឱ្យងាប់ដំណាំតែម្តង។ ការដាក់ជីអ៊ុយរ៉េជិតកូនដំណាំពេក ធ្វើឱ្យខ្លោចឫសនិងដើម។ ***




**រូបទី១** ការលូតលាស់នៃដំណាំនៅលើក្រុមដីព្រៃខ្មែរដែលប្រើប្រាស់ជីតាមក៏រិតណែនាំ **(A)** ប្រៀបធៀបទៅនឹងទំលាប់កសិករ **(B)**

---

[1] Dierolf T., Fairhurst T., and Mutert E. (2001). Soil Fertility Kit. GTZ-GmbH, FAO, PT Jasa Katom, and PPI and PPIC. Oxford Graphic Printer.

[2] White PF., Oberthur T., and Pheav Sovuthy (1997). The Soils Used for Rice Production in Cambodia: A manual for their identification and management. IRRI, PO Box 933, Manila, Philippines.

[3] Cambodia-IRRI-Australia Project (1999). Fertilizer rates for rice. AGNotes, No. INM 99/01. Phnom Penh, Cambodia.

សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យវិទ្យាសាស្ត្រដី និងទឹក មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កសិកម្មកម្ពុជា ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ,ទូរសព្ទ័លេខ:(៨៥៥-២៣)២១៩ ៦៩៣-៤

ទូរសារលេខ: (៨៥៥-២៣) ២១៩ ៨០០ ទូរអក្ខរ: cardi@cardi.org.kh វ៉ែបសាយ: www.cardi.org.kh

VSeng@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh